United Nations Human Rights

OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS
Cambodia Country Office - Phnom Penh - Cambodia

# មតិយោបល់អំពីបទប្បញ្ញត្តិមួយចំនួននៃសេចក្តីព្រាងច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទាក់ទងនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ

## ខែឧសភា ឆ្នាំ២០១៤

មតិយោបល់ខាងក្រោមនេះ ត្រូវបានរៀបរៀងតាក់តែងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ក្នុងគោលបំណងដើម្បីជួយជ្រោមជ្រែងដល់ដំណើរការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ចាប់ពីពេលនេះទៅហៅថា សេចក្តីព្រាងច្បាប់)។ មតិយោបល់ទាំងនេះ មានមូលដ្ឋានជាបឋមផ្អែកលើកាតព្វកិច្ចសិទ្ធិមនុស្សជាអន្តរជាតិរបស់កម្ពុជា ក៏ដូចជាលិខិតុបករណ៍អន្តរជាតិ និងលិខិតុបករណ៍តំបន់នានាដែលពាក់ព័ន្ធស្តីពីឯករាជភាពតុលាការ។

មតិយោបល់ទាំងនេះ ដាក់ជូនចំពោះបទបញ្ញត្តិនៃសេចក្តីព្រាងច្បាប់ថ្មីបំផុត ដូចត្រូវបានពិភាក្សានៅចំពោះមុខរដ្ឋសភា។ មតិយោបល់ទាំងនេះក៏ផ្តោតផងដែរលើវិស័យផ្សេងៗ ដែលការិយាល័យ OHCHR ជឿជាក់ថា គួរត្រូវដាក់បញ្ចូលក្នុងច្បាប់នេះ។ យើងសូមកោតសរសើរថា កំណែទម្រង់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបច្ចុប្បន្ន គឺជាតម្រូវការចាំបាច់ ហើយយល់ឃើញថា ច្បាប់ថ្មីនេះ គឺជាឱកាសតែមួយគត់ ដើម្បីធ្វើឲ្យប្រសើរឡើង និងពង្រឹងដល់ស្ថាប័នដ៏សំខាន់មួយនេះ ដែលដើរតួនាទីស្នូលក្នុងការការពារ និងការលើកស្ទួយឯករាជភាពតុលាការកម្ពុជា។

*ដើម្បីជាប្រយោជន៍ដល់ការបង្កើតនូវការអនុវត្តល្អៗ ការិយាល័យឧត្តមស្នងការសូមផ្តល់អនុសាសន៍ថា គួរតែរៀបចំឲ្យមានកិច្ចពិគ្រោះយោបល់ជាសាធារណៈមួយ ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់នេះ។ នៅក្នុងន័យនេះ ការិយាល័យឧត្តមស្នងការ ត្រៀមខ្លួនជាស្រេច ដើម្បីផ្តល់ជាជំនួយក្នុងការរៀបចំកិច្ចពិគ្រោះយោបល់ជាសាធារណៈបែបនេះ។ លើសពីនេះ ការិយាល័យឧត្តមស្នងការ ត្រៀមខ្លួនជាស្រេច ដើម្បីធ្វើការបង្ហាញជូនដល់សមាជិករដ្ឋសភា និងព្រឹទ្ធសភា អំពីការវិភាគរបស់ខ្លួនទៅលើច្បាប់នេះតាមទស្សនៈវិស័យនៃកាតព្វកិច្ចសិទ្ធិមនុស្សជាអន្តរជាតិរបស់កម្ពុជា។*

## ១/. គោលការណ៍ទូទៅ

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានបង្កើតឡើង ដើម្បីការពារគោលការណ៍ដូចខាងក្រោមនេះ៖

- គោលការណ៍ឯករាជភាពរបស់តុលាការ និងចៅក្រម
- គោលការណ៍នៃការបែងចែកអំណាច (នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ)
- គោលការណ៍អនាគតិរបស់ចៅក្រម

គោលការណ៍ជាមូលដ្ឋានទាំងនេះ ត្រូវបានតំកល់ទុកក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ១៩៦៦ (ICCPR) ដែលប្រទេសកម្ពុជាបានក្លាយជារដ្ឋភាគីក្នុងឆ្នាំ១៩៩២។ យោងតាមមាត្រា៣១ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ICCPR គឺជាផ្នែកមួយនៃច្បាប់កម្ពុជា។

បទបញ្ញត្តិនៃ ICCPR ដែលពាក់ព័ន្ធបំផុត គឺមាត្រា១៤ ដែលការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ បទបញ្ញត្តិនេះរួមមានសិទ្ធិទទួលបានសវនាការជាសាធារណៈដោយ "សាលាជំរះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់" ។ គណៈកម្មាធិការសិទ្ធិមនុស្សដែលជាស្ថាប័នឃ្លាំមើលអន្តរជាតិបង្កើតឡើងដោយ ICCPR បានអនុម័តសេចក្តីពន្យល់ទូទៅលេខ៣២ អំពីមាត្រា១៤ ដែលចែងពីការណែនាំលំអិតដល់រដ្ឋភាគីពីរបៀបបកស្រាយមាត្រា១៤។[1] ក្នុងឯកសារនេះ គណៈកម្មាធិការសិទ្ធិមនុស្សបានរំលឹកថា តុលាការគួរតែឯករាជ្យពីស្ថាប័ននីតិប្រតិបត្តិ និងនីតិបញ្ញត្តិរបស់រដ្ឋាភិបាល។[2]

គោលការណ៍ទាំងឡាយបានលើកឡើងខាងលើ ក៏រាប់បញ្ចូលផងដែរក្នុងគោលការណ៍ជាមូលដ្ឋាន របស់សហប្រជាជាតិស្តីពីឯករាជ្យនៃប្រព័ន្ធតុលាការ និងគោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះ រាជអាជ្ញា។[3] គោលការណ៍ទាំងនេះចែងយ៉ាងច្បាស់ក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រង់ជំពូកស្តីពីប្រព័ន្ធតុលាការ។

## ២/. សមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ស្របតាមគោលការណ៍ឯករាជភាពតុលាការ រាល់សេចក្តីសម្រេចទាក់ទងនឹងការតែងតាំង ការតម្លើងសក្តិ ការព្យួរមុខងារ គួរត្រូវធ្វើឡើងដោយស្ថាប័នមួយដែលមានឯករាជ្យទាំងស្រុងពីអង្គការនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ។ ក្នុងករណីនេះ ធម្មនុញ្ញអឺរ៉ុបស្តីពីលក្ខន្តិកៈចៅក្រម ចែងថា ស្ថាប័ននេះគួរតែជា៖

---

[1] See full text of General Comment No.32 on Article 14 at http://cambodia.ohchr.org/EN/PagesFiles/PublicationsIndex.htm

[2] See General Comment No.32 on Article 14, para.18.

[3] Both documents are available at http://cambodia.ohchr.org/EN/PagesFiles/PublicationsIndex.htm

"អាជ្ញាធរមួយឯករាជ្យពីអំណាចនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ ដែលនៅក្នុងនោះយ៉ាងហោចណាស់ ត្រូវមានចៅក្រមចំនួនពាក់កណ្ដាលជាសមាជិក ដែលត្រូវបោះឆ្នោតជ្រើសរើសដោយសហការីជាចៅក្រមរបស់ខ្លួន។"[4]

ក្រុមប្រឹក្សាពិគ្រោះយោបល់នៃចៅក្រមអឺរ៉ុបមានយោបល់ថា ស្ថាប័នដែលខ្លួនចង់សំដៅដល់នេះ គឺក្រុមប្រឹក្សានៃអង្គចៅក្រមនេះឯង ដែលគួរមានសមាសភាពចម្រុះនៃចៅក្រម និងមិនមែនជាចៅក្រម។[5] សមាជិកភាគច្រើន គួរតែជាចៅក្រមដែលត្រូវបោះឆ្នោតជ្រើសរើសដោយសហការីនៃចៅក្រមនោះ។[6] សមាជិកមិនមែនចៅក្រមអាចរាប់បញ្ចូល "អ្នកច្បាប់ដែលមានកេរ្តិ៍ឈ្មោះ សាស្ត្រាចារ្យមហាវិទ្យាល័យ ដោយមានរយៈពេលបំរើការងារវិជ្ជាជីវៈជាក់លាក់ ឬជាប្រជាពលរដ្ឋដែលឋានៈរបស់ខ្លួនត្រូវបានទទួលស្គាល់។"[7] មិនមានរដ្ឋមន្ត្រីណាម្នាក់អាចជាសមាជិកនៃក្រុមប្រឹក្សានៃអង្គចៅក្រមទេ។[8] ចំពោះវិធីសាស្ត្រជ្រើសរើសវិញ ក្រុមប្រឹក្សាពិគ្រោះយោបល់ "មិនតស៊ូមតិលើប្រព័ន្ធដែលពាក់ព័ន្ធនឹងអាជ្ញាធរនយោបាយ ដូចជាសភា ឬនីតិប្រតិបត្តិ នៅដំណាក់កាលណាក៏ដោយនៃដំណើរការជ្រើសរើស។"[9] ប្រសិនបើប្រព័ន្ធនោះនៅតែត្រូវបានអនុម័ត ហើយសមាជិកមិនមែនចៅក្រមណាមួយត្រូវបានជ្រើសរើសដោយសភា ពួកគេមិនគួរជាសមាជិកសភាទេ ហើយ"គួរត្រូវបោះឆ្នោតជ្រើសរើសដោយសម្លេងភាគច្រើនដែលមានគុណវុឌ្ឍគ្រប់គ្រាន់ ដែលចាំបាច់សម្រាប់ការគាំទ្រពីក្រុមប្រឆាំងដ៏សំខាន់។"[10]

បញ្ហាសមាសភាពនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានសារសំខាន់ខ្លាំងណាស់ដើម្បីធានាពីឯករាជភាព និងសមត្ថភាពរបស់ខ្លួន ក្នុងកិច្ចធានាការពារឯករាជភាពតុលាការ។ ជាទូទៅ គេយល់ឃើញថា សមាសភាពបច្ចុប្បន្ននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាកត្តាចំបងមួយដែលបានរារាំងស្ថាប័ននេះពីការបំពេញតួនាទីរបស់ខ្លួនក្នុងការការពារ និងការលើកស្ទួយឯករាជភាពរបស់ចៅក្រម។ ក្នុងករណីនេះ អ្នករាយការណ៍ពិសេសអំពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជាបានផ្តល់អនុសាសន៍ថា ច្បាប់បច្ចុប្បន្នស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម "គប្បីត្រូវធ្វើវិសោធនកម្ម ដើម្បីធ្វើឲ្យស្ថាប័ននេះជាស្ថាប័នឯករាជ្យមួយពិតប្រាកដ។ ការណ៍នេះនឹងពង្រឹងឯករាជភាពរបស់តុលាការ ដោយការដកចេញនូវធាតុផ្សំបច្ចុប្បន្ននៃការគ្រប់គ្រងដោយនីតិប្រតិបត្តិ និងដាក់បង្ហាញនូវនីតិវិធីបែបប្រជាធិបតេយ្យ និងមានតម្លាភាពមួយ សម្រាប់ការជ្រើសរើស និងការតែងតាំងសមាជិកនានា។"[11]

---

[4] Para.4.1.
[5] See para.16 of Opinion no 10 (2007) of the Consultative Council of European Judges (CCJE) to the attention of the Committee of Ministers of the Council of Europe on the Council for the Judiciary at the service of society, available at https://wcd.coe.int/ViewDoc.jsp?Ref=CCJE%282007%29OP10&Language=lanEnglish&Ver=original&Site=COE&BackColorInternet=FEF2E0&BackColorIntranet=FEF2E0&BackColorLogged=c3c3c3
[6] Para.18.
[7] Para.22.
[8] Para.23.
[9] Para.31.
[10] Para.32.
[11] A/HRC/15/46, para.72.

យើងក៏គួរកត់សម្គាល់ផងដែរថា "ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម-Conseil Supérieur de la Magistrature" នៅប្រទេសបារាំង(ដែលឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរបស់ប្រទេសកម្ពុជាបានយកគំរូតាមនោះ) ត្រូវបានធ្វើកំណែទម្រង់នៅឆ្នាំ២០០៨ ហើយមិនមានសមាជិកណាមួយមកពីនីតិប្រតិបត្តិទៀតទេ។[12]នៅប្រទេសថៃ គណៈកម្មាធិការសេវាកម្មតុលាការ ដែលទទួលខុសត្រូវក្នុងការតែងតាំង ការតម្លើងឋានន្តរសក្តិ និងការដកហូតចៅក្រម មិនរាប់បញ្ចូលសមាជិកណាមួយពីនីតិប្រតិបត្តិដែរ។ គណៈកម្មាធិការនេះ មានសមាសភាពមកពីប្រធានតុលាការកំពូលជាប្រធាន ចៅក្រម១២រូប ជ្រើសរើសដោយការបោះឆ្នោតពីតុលាការគ្រប់ជាន់ថ្នាក់ និងសមាជិក២រូបទៀតមិនមែនចៅក្រម ត្រូវបោះឆ្នោតជ្រើសតាំងដោយព្រឹទ្ធសភា។[13]

សេចក្តីព្រាងនេះ បោះជំហានខ្លះទៅតាមវិធីបែបនេះ ដោយព្យាយាមកែទម្រង់សមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយបង្កើនសមាជិកជាចៅក្រមតាមការបោះឆ្នោតដោយចៅក្រម និងព្រះរាជអាជ្ញា ជាងសមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបច្ចុប្បន្ននេះ។ តាមមាត្រា ៤ នៃសេចក្តីព្រាងច្បាប់នេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមថ្មី នឹងរួមមានផងដែរនូវអ្នកច្បាប់បីរូបមានបទពិសោធន៍ (ដែលសព្វថ្ងៃនេះ មិនមែនជាសមាជិកតុលាការ) បោះឆ្នោតជ្រើសតាំងដោយរដ្ឋសភា ព្រឹទ្ធសភា និងក្រុមប្រឹក្សាធម្មនុញ្ញ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមថ្មី ក៏នឹងរាប់បញ្ចូលផងដែរនូវព្រះរាជអាជ្ញាមួយរូបតែងតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ តាមសេចក្តីព្រាងនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៅតែជាសមាជិកមួយរូបនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ យោងតាមស្មារតីនៃគោលការណ៍នៃការបែងចែកអំណាច សមាជិកមួយរូបមកពីនីតិប្រតិបត្តិ មិនគួរជាផ្នែកមួយនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទេ ដែលជាស្ថាប័នសំខាន់ទទួលបន្ទុកខាងតុលាការ។ សំរាប់ហេតុផលដូចគ្នានេះ នីតិប្រតិបត្តិមិនគួរពាក់ព័ន្ធក្នុងការជ្រើសរើសសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទេ។

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា មាត្រា៤ ត្រូវធ្វើការកែសម្រួលដោយដកចេញពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនូវសមាជិកណាមួយដែលមកពីនីតិប្រតិបត្តិ ឬសមាជិកណាមួយដែលតែងតាំងដោយនីតិប្រតិបត្តិ។ ដើម្បីឲ្យមានចំនួនភាគច្រើននៃចៅក្រមដែលត្រូវបោះឆ្នោតជ្រើសតាំង បញ្ជីនៃសមាជិកដែលស្នើសុំអាចដាក់បញ្ចូល៖*

- *ប្រធានតុលាការកំពូល — សមាជិកក្នុងតំណែង*
- *អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល — សមាជិកក្នុងតំណែង*
- *អតីតចៅក្រម ព្រះរាជអាជ្ញា ឬអ្នកច្បាប់លេចធ្លោ សាស្ត្រាចារ្យសកលវិទ្យាល័យ ដោយមានរយៈពេលដាក់លាក់ក្នុងការបំរើវិជ្ជាជីវៈ ឬជាពលរដ្ឋដែលឋានៈរបស់ខ្លួន*

[12] See http://www.vie-publique.fr/decouverte-institutions/justice/personnel-judiciaire/magistrats/qu-est-ce-que-conseil-superieur-magistrature.html
[13] See http://d-arch.ide.go.jp/idedp/IAL/IAL000600_006.pdf

*ត្រូវបានទទួលស្គាល់ដោយការបោះឆ្នោតជ្រើសតាំងដោយព្រឹទ្ធសភា(តែមិនមែនជាសមាជិកព្រឹទ្ធសភាទេ)*

- *អតីតចៅក្រម ព្រះរាជអាជ្ញា ឬអ្នកច្បាប់លេចធ្លោ សាស្ត្រាចារ្យសកលវិទ្យាល័យ ដោយមានរយៈពេលជាក់លាក់ក្នុងការបំពេញវិជ្ជាជីវៈ ឬជាពលរដ្ឋដែលឋានៈរបស់ខ្លួនត្រូវបានទទួលស្គាល់ដោយការបោះឆ្នោតជ្រើសតាំងដោយរដ្ឋសភា (តែមិនមែនជាសមាជិករដ្ឋសភាទេ)*
- *ចៅក្រមពីតុលាការជាន់ខ្ពស់ (តុលាការកំពូល ឬសាលាឧទ្ធរណ៍) បោះឆ្នោតជ្រើសរើសដោយចៅក្រមមានឋានៈស្មើគ្នា*
- *ព្រះរាជអាជ្ញាពីតុលាការជាន់ខ្ពស់ បោះឆ្នោតជ្រើសរើសដោយព្រះរាជអាជ្ញាមានឋានៈស្មើគ្នា*
- *ចៅក្រមពីសាលាដំបូង បោះឆ្នោតជ្រើសរើសដោយចៅក្រមមានឋានៈស្មើគ្នា*
- *ព្រះរាជអាជ្ញាពីសាលាដំបូង បោះឆ្នោតជ្រើសរើសដោយព្រះរាជអាជ្ញាមានឋានៈស្មើគ្នា*

ចំពោះរយៈពេលនៃអាណត្តិរបស់សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មាត្រា ៥ចែងថា សមាជិកបោះឆ្នោតជ្រើសតាំង មានអាណត្តិរយៈពេល៥ឆ្នាំ។ ហើយហាក់ដូចជាមិនមានការកំណត់ណាមួយពីចំនួនអាណត្តិឡើយ។ ដើម្បីធានាដល់ការផ្លាស់ប្តូរជាទៀងទាត់ ក្នុងសមាសភាពនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ការកំណត់ចំនួនអាណត្តិគឺជាប្រការមួយសមរម្យថែមទៀត។

យោងតាមមាត្រា៦ សមាជិកជាចៅក្រមដែលត្រូវបានបោះឆ្នោតជ្រើសតាំង ត្រូវបំពេញការងារពេញម៉ោង ដែលនឹងជួយឲ្យការងាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកាន់តែមានប្រសិទ្ធភាព។ នេះគឺជាអនុសាសន៍មួយពីអ្នករាយការណ៍ពិសេសអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។[14] ទោះបីជាយ៉ាងណាក៏ដោយ បញ្ហានេះនៅតែមានសារសំខាន់ ដើម្បីធានាថា ចៅក្រមដែលធ្វើការនៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម "មិនត្រូវអវត្តមានយូរពេកពីការងារតុលាការរបស់ខ្លួន ធ្វើដូច្នេះ ដើម្បីឲ្យចៅក្រមនៅតែរក្សាបាននូវទំនាក់ទំនងជាមួយការអនុវត្តន៍ការងារតុលាការរបស់ខ្លួន នៅពេលណាអាចវិលទៅបំពេញការងារនៅតុលាការវិញ។"[15] ក្នុងករណីនេះ ចៅក្រម និងព្រះរាជអាជ្ញាដែលត្រូវបានបោះឆ្នោតជ្រើសតាំង មិនចាំបាច់ត្រូវអង្គុយក្នុងសមាសភាពនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងរយៈពេលជាច្រើនឆ្នាំជាប់ៗគ្នា។

---

[14] A/HRC/15/46, para.73.

[15] See para.34 of Opinion no 10 (2007) of the Consultative Council of European Judges (CCJE) to the attention of the Committee of Ministers of the Council of Europe on the Council for the Judiciary at the service of society.

*ការិយាល័យ* OHCHR *សូមផ្តល់អនុសាសន៍ ឲ្យដាក់បញ្ចូលនូវការកំណត់ចំនួនអាណត្តិ ក្នុងមាត្រា៥។ ក្នុងកថាខ័ណ្ឌទី១ យើងអាចបន្ថែមនូវប្រយោគមួយដូចខាងក្រោមនេះ៖ ចំនួនអាណត្តិ ត្រូវបានកំណត់ត្រឹមតែ២ដងប៉ុណ្ណោះ*

មាត្រា២៨ ចែងថា ការបោះឆ្នោតជ្រើសរើសតំណាងពីចៅក្រម និងព្រះរាជអាជ្ញា នឹងត្រូវធ្វើឡើងក្នុងរយៈពេល៣ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ប៉ុន្តែហាក់ដូចជាមិនមានការបង្ហាញពីពេលវេលាសម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកដែលមិនមែនជាចៅក្រមឡើយ។

*ការិយាល័យ* OHCHR *សូមផ្តល់អនុសាសន៍ ឲ្យបញ្ជាក់ច្បាស់នៅក្នុងមាត្រា២៨ ពីពេលវេលាដាក់លាក់សំរាប់ការបោះឆ្នោតជ្រើសរើសសមាជិកដែលត្រូវជ្រើសតាំងទាំងអស់របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីធានាថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងសមាសភាពថ្មីរបស់ខ្លួន អាចចាប់ផ្តើមប្រព្រឹត្តទៅឲ្យបានឆាប់រហ័សតាមតែអាចធ្វើបាន។*

## ៣/.ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ដើម្បីឲ្យមានប្រសិទ្ធភាព ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរមានធនធានគ្រប់គ្រាន់ ដើម្បីបំពេញបេសកកម្មរបស់ខ្លួន។ ជាពិសេស វាមានសារសំខាន់ ដែលឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវមាន៖

> "ទីតាំងធ្វើការផ្ទាល់របស់ខ្លួន លេខាធិការដ្ឋាន ធនធានបំពេញការងារតាមកុំព្យូទ័រ និងសេរីភាពចាត់ចែងដោយខ្លួនឯង ដោយមិនចាំបាច់ឆ្លើយតបពីសកម្មភាពរបស់ខ្លួនទៅនឹងអាជ្ញាធរនយោបាយ ឬអាជ្ញាធរដទៃទៀត។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគួរមានសេរីភាពរៀបចំរចនាសម្ព័ន្ធរបស់ខ្លួន និងរៀបចំរបៀបវារៈប្រជុំរបស់ខ្លួន ក៏ដូចជាមានសិទ្ធិប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយតុលាការ ដើម្បីអនុវត្តមុខងាររបស់ខ្លួន។"[16]

តាមមាត្រា៨ លេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតនៅក្រោមក្រសួងយុត្តិធម៌។ ដើម្បីធានាការពារឯករាជភាពពេញលេញរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លេខាធិការដ្ឋានរបស់ខ្លួន គួរត្រូវស្ថិតនៅដោយឡែក និងមានស្វ័យភាព។

*ការិយាល័យ* OHCHR *សូមផ្តល់អនុសាសន៍ ឲ្យលុបចោល នៅក្នុងមាត្រា៨ នូវឃ្លា "ស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌"។*

[16] See para.38 of Opinion no 10 (2007) of the Consultative Council of European Judges (CCJE) to the attention of the Committee of Ministers of the Council of Europe on the Council for the Judiciary at the service of society.

មាត្រា១០ ចែងថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវកោះប្រជុំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ដូចបានរៀបរាប់ខាងលើ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគួរមានសេរីភាពក្នុងការរៀបចំការប្រជុំរបស់ខ្លួននិងសំរេចពីអ្វីដែលខ្លួនចង់ពិភាក្សា។ វាមិនគួរជាបុព្វសិទ្ធិរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងការកោះប្រជុំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនោះទេ។

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ឲ្យកែសម្រួលមាត្រា១០ ដូចខាងក្រោម៖ ប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវកោះប្រជុំតាមសំណើររបស់សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម យ៉ាងហោចណាស់៤រូប។*

មាត្រា១១ ចែងពីបញ្ហាកូរ៉ុម ដែលត្រូវមានសមាជិក៦រូប។ តាមសមាសភាពដូចបានកំណត់ក្នុងមាត្រា៤ ដែលមានន័យថាការប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចប្រព្រឹត្តទៅបាន និងអនុម័តសេចក្តីសំរេច ដោយមិនចាំបាច់មានអ្នកតំណាងចៅក្រម ឬព្រះរាជអាជ្ញា បួនរូប ចេញពីការបោះឆ្នោតទេ។ បើមាត្រា៤ នៅតែចែងដូចនេះ កូរ៉ុមគួរតែកំណត់ច្រើនជាង៧រូប ដើម្បីធានាថា យ៉ាងហោចណាស់មានអ្នកតំណាងចៅក្រម ឬព្រះរាជអាជ្ញាមួយរូបចេញពីការបោះឆ្នោត មានវត្តមាន និងចូលរួមក្នុងការធ្វើសំរេចសម្រេច។

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា ក្នុងមាត្រា១១ កូរ៉ុមគួរកំណត់ត្រឹមចំនួនមួយ ដែលធានាថា គ្មានការប្រជុំ និងការសម្រេចណាអាចប្រព្រឹត្តទៅបាន ដោយគ្មានយ៉ាងហោចណាស់ សមាជិកជាចៅក្រមជាប់ឆ្នោតម្នាក់ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទេ។ វិធាននេះ គួរយកមកអនុវត្តសំរាប់ការអនុម័តវិធានផ្ទៃក្នុងរបស់ខ្លួន តាមមាត្រា១៤ដែរ។*

មាត្រា១៥ ចែងថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវមានថវិការបស់ខ្លួនផ្ទាល់ ដែលត្រូវបានស្វាគមន៍។ ទោះបីជាយ៉ាងនេះក៏ដោយ មាត្រា១៥ ក៏ចែងដែរថា មានតែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ទេដែលអាចអនុញ្ញាតិដល់ការចំណាយថវិកានេះ។ ដើម្បីទុកលទ្ធភាពឲ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចាយវាយថវិការបស់ខ្លួនដោយឯករាជ្យ និងស្វ័យភាព វាសមរម្យជាងបើសិនជាប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ដែលមិនមែនជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌) ជាអ្នកមានអំណាចយល់ព្រមលើចំនាយរបស់ខ្លួន។

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា មាត្រា១៥ គួរត្រូវបានកែសម្រួលដូច្នេះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន។*

មាត្រា១៨ ចែងពីអាណត្តិរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ដូចបានអធិប្បាយនៅក្នុងមតិយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ការសម្រេចពីការតំឡើងឋានន្តរសក្តិ អាចសំរេចដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាជាងដោយគណៈកម្មាធិការតំឡើងឋានន្តរស័ក្តិដាច់ដោយឡែកមួយ។ យោងតាមមាត្រា១៨ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចផ្តល់អនុសាសន៍ លើការតែងតាំង ការផ្លាស់ប្តូរមុខតំណែង។ល។ *តែតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ប៉ុណ្ណោះ*។ តាមស្មារតីនៃគោលការណ៍នៃការបែងចែកអំណាច អំណាចនីតិប្រតិបត្តិមិនគួរមានយោបល់អ្វីទេ នៅក្នុងបញ្ហាទាំងនេះ ទាក់ទងនឹងតុលាការ។

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ ឲ្យបន្ថែមក្នុងមាត្រា១៨ នូវពាក្យ "ការតំឡើងឋានន្តរស័ក្តិ" ដល់បញ្ជីបញ្ហាដែលឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចសម្រេច និងលុបចោលឃ្លា "តាមការស្នើសុំពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌" នៅក្នុងកថាខណ្ឌទី២។*

សព្វថ្ងៃនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគ្មានអំណាចជាក់លាក់ណាមួយ ក្នុងការតែងតាំងស្ត្រីនៅក្នុងវិស័យតុលាការទេ។ ទោះជាចំនួនស្ត្រីជាចៅក្រម និងព្រះរាជអាជ្ញា មានចំនួនកាន់តែកើនឡើងក្នុងបណ្តាឆ្នាំថ្មីៗនេះក៏ដោយ ក៏ចំនួនចៅក្រមស្ត្រីមានចំនួនប្រហែលតែ៥០នាក់ប៉ុណ្ណោះ ក្នុងចំណោមចៅក្រម និងព្រះរាជអាជ្ញា សរុប៤០០នាក់។ ទន្ទឹមនឹងនោះ មានសមាជិកជាស្ត្រីតែម្នាក់គត់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។

ក្នុងឆ្នាំ២០០៦ គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) បានផ្តល់អនុសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុម័ត "វិធានការនានា ដែលនឹងជួយដល់ការបង្កើនចំនួនស្ត្រីនៅក្នុងមុខតំណែងដែលទទួលបានដោយការបោះឆ្នោត និងការតែងតាំងរួមទាំងក្នុងវិស័យតុលាការ។[17] គណៈកម្មាធិការបានផ្តល់អនុសាសន៍ស្រដៀងគ្នាកាលពីឆ្នាំ២០១៣។[18] វិធានការទាំងនេះ គួររាប់បញ្ចូលទាំងវិធានការពិសេសបណ្តោះអាសន្ន ដើម្បីលើកស្ទួយស្ត្រីឲ្យកាន់តែសកម្ម ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយការយល់ដឹង។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រដែលត្រូវកែសម្រួល គួរមានអាណត្តិជាក់លាក់ ដើម្បីលើកស្ទួយស្ត្រីក្នុងវិជ្ជាជីវៈតុលាការ ស្របតាមអនុសាសន៍នេះ។

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ ឲ្យបន្ថែមមួយប្រយោគ ក្នុងមាត្រា១៨ ដូចខាងក្រោម៖*

*ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវអនុម័តវិធានការនានា ដើម្បីធ្វើឲ្យប្រសើរដល់ការបែងចែក និងភាពជាតំណាងយេនឌ័រ នៅក្នុងតុលាការ រួមទាំងតុលាកាជាន់ខ្ពស់ដែរ។*

---

[17] CEDAW/C/KHM/CO/3, para.24.
[18] CEDAW/C/KHM/CO/4-5, para.29.

## ៨/. ទោសបញ្ញត្តិ

នៅពេលដែលនិយាយពីទោសបញ្ញតិប្រឆាំងនឹងចៅក្រម និងព្រះរាជអាជ្ញា គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិ ស្តីពីឯករាជ្យភាពតុលាការ រំលឹកថា៖

> "ការចោទប្រកាន់ ឬការប្តឹងជំទាស់ចំពោះចៅក្រមម្នាក់ ក្នុងសមត្ថភាពវិជ្ជាជីវៈ និងតុលាការរបស់គាត់ ត្រូវដំណើរការឲ្យបានឆាប់ និងត្រឹមត្រូវ តាមនីតិវិធីសមរម្យ។ ចៅក្រមរូបនេះ ត្រូវមានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ការពិនិត្យលើបញ្ហានេះ នៅតំណាក់កាលដំបូង ត្រូវរក្សាជាការសំងាត់ លើកលែងតែមានសំណើផ្សេងពីនេះ ស្នើសុំដោយចៅក្រមសាម៉ី។"[19]

គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា មានបទបញ្ញត្តិប្រហាក់ប្រហែលគ្នា។[20] បន្ថែមពីនេះ សេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំងនៃគោលការណ៍ស្តីពីឯករាជភាពតុលាការ បោះពុម្ពក្នុងព្រឹត្តិប័ត្រ "តំបន់ច្បាប់អាស៊ី" (អនុម័តដោយប្រធានតុលាការកំពូលនៃតំបន់ច្បាប់អាស៊ី និងចៅក្រមផ្សេងទៀតពីអាស៊ីនិងប៉ាស៊ីហ្វិច រៀបចំឡើងនៅប៉េកាំង កាលពីឆ្នាំ ១៩៩៥ និងត្រូវបានអនុម័តដោយក្រុមប្រឹក្សាច្បាប់អាស៊ី ក្នុងឆ្នាំ២០០១ ចែងថា៖

> "សេចក្តីសំរេចក្នុងដំណើរការដាក់ពិន័យ ទោះជានៅក្នុងសវនាកាអសាធារ ឬក៏សាធារណៈ គួរត្រូវបានផ្សព្វផ្សាយ។"[21]

ទាក់ទងនឹងសិទ្ធិនៃការប្តឹងឧទ្ធរណ៍ លិខិតូបករណ៍អន្តរជាតិរំលឹកថា សេចក្តីសម្រេចនៅក្នុងនីតិវិធីដាក់វិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញា គួរត្រូវបានពិនិត្យឡើងវិញដោយឯករាជ្យ។[22]

ផ្នែកទី២ នៃជំពូកទីIV និយាយពីសមត្ថកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការដាក់វិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញា។ មាត្រា២០ ចែងថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនត្រូវចូលរួមក្នុងក្រុមប្រឹក្សាវិន័យទេ លើកលែងតែក្នុងករណីចាត់វិធានការវិន័យចំពោះប្រធាន និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ ដើម្បីការពារឯករាជភាពចៅក្រម និងព្រះរាជអាជ្ញា ករណីលើកលែងនេះ មិនត្រូវធ្វើយុត្តិកម្មទេ- នីតិប្រតិបត្តិ មិនគួរជាប់ទាក់ទងនឹងវិធានការវិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញា ក្រោមកាលៈទេសៈណាមួយនោះទេ។

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ លុបចោលប្រយោគចុងក្រោយនៃវក្យខ័ណ្ឌទី២ នៃមាត្រា២០។*

---

[19] Para.17.
[20] Para.21.
[21] Para.28. Available at http://lawasia.asn.au/beijing-statement.htm
[22] See Basic Principles on the Independence of the Judiciary, para.20 and Guidelines on the Role of Prosecutors, para.21.

មាត្រា២៣ និយាយពីយន្តការបណ្តឹង។ ដោយសារបណ្តឹង ត្រូវដាក់ជូនលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មិនត្រូវមានការធ្វើយុត្តិកម្មដល់ការមានប្រព័ន្ធបន្ថែមមួយទៀត ក្នុងការទទួលពាក្យបណ្តឹង និងការស៊ើបសួរលើពាក្យបណ្តឹងនៅក្រសួងយុត្តិធម៌នោះទេ។ នៅក្នុងករណីណាក៏ដោយ អំណាចនីតិប្រតិបត្តិ មិនត្រូវជាប់ទាក់ទងក្នុងដំណើរការនីតិវិធី និងការស៊ើបសួរលើបណ្តឹងប្រឆាំងនឹងចៅក្រម និងព្រះរាជអាជ្ញាឡើយ - បណ្តឹង គួរត្រូវដាក់ទៅតែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែប៉ុណ្ណោះ គឺមិនមែនត្រូវដាក់ទៅក្រសួងយុត្តិធម៌នោះទេ។

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ឲ្យកែសម្រួលមាត្រា២៣និង២៤ ដោយពាក្យបណ្តឹងត្រូវដាក់ទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម(មិនមែនដាក់ទៅស្ថាប័នដទៃផ្សេងនោះទេ)។ មានតែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមប៉ុណ្ណោះ ត្រូវចាត់នីតិវិធី ឲ្យស៊ើបអង្កេតលើពាក្យបណ្តឹងនេះ។ បញ្ញត្តិនៃមាត្រាទាំងពីរនេះ គួរត្រូវអានដូចខាងក្រោម៖*

*មាត្រា២៣៖ ពាក្យបណ្តឹងដែលទាក់ទងនឹងទោសពិន័យប្រឆាំងនឹងចៅក្រម និងព្រះរាជអាជ្ញា ត្រូវដាក់ទៅលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។*

*មាត្រា២៤៖ បន្ទាប់ពីទទួលបានពាក្យបណ្តឹង ហើយបើសិនជាឃើញថាចាំបាច់ប្រធានក្រុមប្រឹក្សាវិន័យ ត្រូវបង្គាប់បញ្ជាឲ្យមានការស៊ើបអង្កេត ដោយប្រើប្រាស់យន្តការនៃក្រុមអធិការកិច្ចរបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។*

មាត្រា២៦ បញ្ជាក់ច្បាស់ថាតើសេចក្តីសម្រេចនៃក្រុមប្រឹក្សាវិន័យ ត្រូវបានបោះពុម្ពផ្សាយ។ មាត្រានេះ ចែងថា សេចក្តីសម្រេចមិនត្រូវបើកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍នោះទេ។

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ ឲ្យមានការកែសម្រួលនូវមាត្រា២៦ដូចខាងក្រោម៖*

*បន្ថែមនៅផ្នែកខាងចុងនៃកថាខណ្ឌទី១ - "សេចក្តីសម្រេចនៃក្រុមប្រឹក្សាវិន័យ ត្រូវបានចុះផ្សាយ។"*

*សូមលុបនៅផ្នែកខាងចុងនៃកថាខណ្ឌទី៣ – "សេចក្តីសម្រេចនេះ មិនត្រូវបើកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍នោះទេ" ហើយប្តូរមកជា "សេចក្តីសម្រេចនេះ អាចត្រូវប្តឹងឧទ្ធរណ៍ទៅតុលាការកំពូលបាន"។*

រៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា<br>ភ្នំពេញថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤